CAMBODIAN
LIVE ATTENUATED

# ថ្នាំបង្ការរោគ គ្រុនផ្តាសាយធំ 2009 H1N1

## ថ្នាំរស់ ដែលខ្សោយ
## *(ថ្នាំបង្ការរោគបាញ់តាមច្រមុះ)*

## អ្វីដែលលោកអ្នកត្រូវដឹង

មានសេចក្តីថ្លែងព័ត៌មានថ្នាំបង្ការរោគ ជាច្រើន ជាភាសាអេស្ប៉ាញ៉ុល និងជាភាសាផ្សេងៗទៀត ។ សូមមើលនៅ www.immunize.org/vis ។

## 1 តើគ្រុនផ្តាសាយធំ 2009 H1N1 ជាអ្វី?

គ្រុនផ្តាសាយធំ 2009 H1N1 (ជួនកាលគេហៅថា Swine Flu) ជាភាសាខ្មែរហៅថា ស្វូករោគគ្រុនផ្តាសាយ ឬគ្រុនផ្តាសាយជ្រូក បានបណ្តាលដោយសារពូជមេរោគវីរុស ថ្មីនៃគ្រុនផ្តាសាយធំ ។ វាបានឆ្លងរាលដាលទៅប្រទេសជាច្រើន ។

ដូចគ្នានឹងមេរោគគ្រុនផ្តាសាយធំផ្សេងៗទៀតដែរ រោគ 2009 H1N1 ឆ្លងរាលដាលពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត តាមរយៈការក្អក ការកណ្តាស់ ហើយជួនកាលតាមរយៈការប៉ះនឹងវត្ថុអ្វីដែលមានប្រឡាក់មេរោគវីរុស ។

សញ្ញានៃរោគ 2009 H1N1 អាចរួមមាន :

- រហឹតរហៃ
- គ្រុនក្តៅ
- ឈឺបំពង់ក
- ឈឺសាច់ដុំ
- ស្រៀវស្រាញ
- ក្អក
- កណ្តាស់

មនុស្សខ្លះទៀតក៏អាចមានការរាករូស និងក្អួតចង្អោរផងដែរ ។

មនុស្សភាគច្រើនបានស្រួលខ្លួនឡើងវិញ ក្នុងពេលមួយអាទិត្យ ។ ប៉ុន្តែមនុស្សមួយចំនួន អាចមានរោគហើមសួត ឬមានជំងឺធ្ងន់ធ្ងរផ្សេងទៀត ។ រីឯមនុស្សខ្លះទៀត នឹងត្រូវចូលសំរាកនៅមន្ទីរពេទ្យ ហើយខ្លះទៀតអាចនឹងស្លាប់ ។

## 2 តើរោគ 2009 H1N1 ខុសគ្នាពីគ្រុនផ្តាសាយធំ (តាមរដូវ) ធម្មតា ដោយរបៀបណា?

មេរោគវីរុសគ្រុនផ្តាសាយធំតាមរដូវ ផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែវាមានភាពស្រដៀងនឹងគ្នាណាស់ ។

មនុស្សដែលធ្លាប់កើតមានគ្រុនផ្តាសាយធំ នៅពេលកន្លងទៅ តាមធម្មតាមានភាពស៊ាំរោគខ្លះ ចំពោះនឹងមេរោគវីរុសគ្រុនផ្តាសាយធំតាមរដូវ (ខ្លួនប្រាណរបស់គេបានកើនសមត្ថភាពខ្លះ ដើម្បីតតាំងនឹងមេរោគវីរុស) ។

មេរោគវីរុសគ្រុនផ្តាសាយធំ 2009 H1N1 គឺជាពូជមេរោគវីរុសគ្រុនផ្តាសាយថ្មីមួយ ។ វាមានភាពខុសគ្នាយ៉ាងខ្លាំង អំពីមេរោគវីរុសគ្រុនផ្តាសាយធំតាមរដូវ ។

មនុស្សភាគច្រើនមានភាពស៊ាំរោគបន្តិចបន្តួច ឬគ្មានភាពស៊ាំរោគសោះ ចំពោះគ្រុនផ្តាសាយធំ 2009 H1N1 (ខ្លួនប្រាណរបស់គេមិនបានប្រុងប្រៀបដើម្បីតតាំងនឹងមេរោគវីរុសឡើយ) ។

## 3 ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ 2009 H1N1

សព្វថ្ងៃនេះមានថ្នាំបង្ការរោគ ដើម្បីការពារប្រឆាំងនឹងគ្រុនផ្តាសាយធំ 2009 H1N1 ។

- ថ្នាំបង្ការរោគទាំងនេះ គឺបានផលិតឡើងដូចគ្នានឹងថ្នាំបង្ការរោគគ្រុនផ្តាសាយធំតាមរដូវដែរ ។
- ថ្នាំទាំងនេះត្រូវបានរំពឹងថាមានសុវត្ថិភាព និងមានប្រសិទ្ធិភាពដូចគ្នានឹងថ្នាំបង្ការរោគគ្រុនផ្តាសាយធំតាមរដូវដែរ ។
- ថ្នាំទាំងនេះនឹងមិនការពារជំងឺ "ដូចគ្រុនផ្តាសាយធំ" ដែលបានបណ្តាលមកពីមេរោគវីរុសផ្សេងៗទៀតឡើយ ។
- ថ្នាំទាំងនេះនឹងមិនការពារគ្រុនផ្តាសាយធំតាមរដូវទេ ។ ***បើអ្នកចង់ការពារកុំឲ្យឆ្លងគ្រុនផ្តាសាយធំតាមរដូវ អ្នកគួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំតាមរដូវផងដែរ ។***

ថ្នាំបង្ការរោគរស់ ដែលខ្សោយបាញ់តាមច្រមុះ **(Live, attenuated intranasal)** ឬហៅកាត់ថា **LAIV** ត្រូវបានបាញ់ចូលទៅច្រមុះ ។ **សន្លឹកនេះរៀបរាប់អំពីថ្នាំបង្ការរោគរស់ ដែលខ្សោយបាញ់តាមច្រមុះ ។**

សព្វថ្ងៃនេះក៏មានថ្នាំបង្ការរោគ**អសកម្ម**ដែរ ដែលត្រូវបានផ្តល់ឲ្យជាថ្នាំចាក់ ។ ព័ត៌មានអំពីថ្នាំនេះ មានរៀបរាប់នៅសន្លឹកមួយដោយឡែកទៀត ។

ថ្នាំ 2009 H1N1 LAIV ពុំមានសារធាតុធីម៉ឺរ៉ូសាល់ (thimerosal) ឬសារធាតុរក្សាទុក ផ្សេងទៀតទេ ។ ថ្នាំនេះបានអនុញ្ញាតសំរាប់មនុស្សអាយុពី 2 ឆ្នាំ រហូត ដល់ 49 ឆ្នាំ ។

ថ្នាំបង្ការមេរោគវីរុស គឺបានខ្សោយ (អន់ខ្សោយ) ដូច្នេះហើយវានឹងមិនបណ្តាលឲ្យមានជំងឺទេ ។

## 4 តើអ្នកណាខ្លះ គួរតែទទួលថ្នាំបង្ការរោគគ្រុនផ្តាសាយធំ 2009 H1N1 និងនៅពេលណា?

### អ្នកណាខ្លះ

ថ្នាំ LAIV បានយល់ព្រមឲ្យប្រើ សំរាប់មនុស្សតាំងពីអាយុ 2 ឆ្នាំ រហូតដល់ 49 ឆ្នាំ ដែលគ្មានផ្ទៃពោះ និងដែលពុំមានលក្ខណៈសុខភាពខ្លះ (មើលលេខ 5 ខាងក្រោម) ។ ក្រុមមនុស្សដែលបានឲ្យយោបល់ដើម្បីទទួលថ្នាំ 2009 H1N1 LAIV ជាដំបូងគេ គឺមនុស្សមានសុខភាពល្អ ដែល :

- មានអាយុតាំងពី 2 ឆ្នាំ រហូតដល់ 24 ឆ្នាំ
- មានអាយុតាំងពី 25 ឆ្នាំ រហូតដល់ 49 ឆ្នាំ និង
  - រស់នៅជាមួយ ឬមើលថែទាំទារក អាយុក្មេងជាង 6 ខែ ឬ
  - អ្នកថែរក្សាសុខភាព ឬបុគ្គលិកពេទ្យផ្នែកសង្គ្រោះភាពអាសន្ន ។

នៅពេលណាមានថ្នាំបង្ការរោគថែមទៀត មនុស្សផ្សេងទៀតដែលមានសុខភាពល្អ ចាប់តាំងពីអាយុ 25 ឆ្នាំ រហូតដល់ 49 ឆ្នាំ ក៏គួរតែបានចាក់ថ្នាំបង្ការរោគដែរ ។

> កំណត់ : មន្ទីមនឹងក្រុមមនុស្សខ្លះមិនគួរទទួលថ្នាំ LAIV បានទេ – ឧទាហរណ៍ដូចជា ស្ត្រីមានផ្ទៃពោះ មនុស្សដែលមានបញ្ហាសុខភាពត្រាំត្រែង និងក្មេងៗ ចាប់ តាំងពីអាយុ 6 ខែ ទៅដល់ 2 ឆ្នាំ – វាគឺជាសារៈសំខាន់ ថាគេត្រូវបានចាក់ថ្នាំបង្ការរោគ ។ គេគួរតែបានចាក់ថ្នាំការពារគ្រុនផ្តាសាយធំ ។

រដ្ឋាភិបាលសហព័ន្ធកំពុងតែផ្តល់ថ្នាំបង្ការរោគនេះ សំរាប់មនុស្សព្រមទទួលដោយស្ម័គ្រចិត្ត ។ តែជាយ៉ាងណាមិញ ច្បាប់រដ្ឋ ឬក្រុមហ៊ុនការងារ អាចនឹងដំរូវឲ្យមានការចាក់ថ្នាំបង្ការរោគ សំរាប់មនុស្សមួយចំនួន ។

### ពេលវេលា

ត្រូវចាក់ថ្នាំបង្ការរោគ យ៉ាងឆាប់រហ័សនៅពេលមានថ្នាំបង្ការរោគ ។

ក្មេងៗមានអាយុរហូតដល់ទៅ 9 ឆ្នាំ គួរតែទទួលថ្នាំបង្ការរោគ**ពីរដូស្ស** គឺពីរគីរតចន្លោះគ្នាប្រហែលជាពីរខែ ។ ក្មេងៗដែលចាស់ជាង និងមនុស្សចាស់ ត្រូវការតែមួយដូស្សប៉ុណ្ណោះ ។

## 5 មនុស្សខ្លះមិនគួរតែទទួលថ្នាំបង្ការរោគទេ ឬគួរតែរង់ចាំ

**បើអ្នកមានប្រតិកម្មធ្ងន់ធ្ងរ (ការគំរាមកំហែងជីវិត) ដោយមានប្រតិកម្មនឹងពងសត្វ ឬសារធាតុអ្វីផ្សេងទៀតនៅក្នុងថ្នាំបង្ការរោគ** អ្នកមិនត្រូវទទួលថ្នាំ 2009 H1N1 LAIV ទេ ។ *បើអ្នកមានប្រតិកម្មធ្ងន់ធ្ងរអ្វីមួយ ត្រូវប្រាប់មនុស្សដែលផ្តល់ថ្នាំបង្ការរោគឲ្យអ្នក ។*

ថ្នាំ 2009 H1N1 LAIV មិនត្រូវបានឲ្យទៅក្រុមមនុស្សនៅខាងក្រោមឡើយ ។
- ក្មេងៗអាយុតិចជាង 2 ឆ្នាំ និងមនុស្សចាស់អាយុ 50 ឆ្នាំ និងចាស់ជាង
- ស្ត្រីមានផ្ទៃពោះ
- មនុស្សណាម្នាក់ ដែលខ្សោយខាងប្រព័ន្ធស៊ាំរោគ
- មនុស្សណាម្នាក់ ដែលមានបញ្ហាសុខភាពត្រាំត្រែង ដូចជា
  - រោគបេះដូង - រោគផ្សំរងនោម ឬរោគថ្លើម
  - រោគសួត - រោគដំណើរបំបែកអាហារ ដូចជារោគទឹកនោមផ្អែម
  - រោគហឺត - រោគខ្វះឈាមក្រហម និងបញ្ហារោគឈាមផ្សេងៗទៀត
- ក្មេងៗអាយុតិចជាង 5 ឆ្នាំ ដែលមានរោគហឺត ឬមានលក្ខណៈមួយ ឬច្រើនជាងនៃការតឹងដង្ហើម នៅក្នុងកំឡុងឆ្នាំកន្លងទៅ
- មនុស្សណាម្នាក់ ដែលមានបញ្ហាខាងសាច់ដុំ ឬសរសៃប្រសាទអ្វីមួយ (ដូចជារោគវិកលខួរក្បាល) ដែលអាចបណ្តាលឲ្យមានបញ្ហាខាងការដកដង្ហើម ឬការលេប
- មនុស្សណាម្នាក់ ដែលនៅជិតស្និទ្ធនឹងជនណាម្នាក់ដែលមានប្រព័ន្ធស៊ាំរោគអន់ខ្សោយ*ជាអនេក* (ដែលត្រូវការថែទាំក្នុងបរិស្ថានដែលការពារ ដូចជាផ្នែកផ្សាំខួរឆ្អឹង)
- ក្មេងៗ ឬក្មេងជំទង់ៗ ដែលទទួលការព្យាបាលដោយប្រើថ្នាំអាស្ពីរីនយូរលង់ ។

បើអ្នកមានជំងឺធុនស្រាល ឬធ្ងន់ធ្ងរ អ្នកអាចទទួលឱវាទឲ្យរង់ចាំទាល់តែអ្នកបានធូរស្បើយសិន មុននឹងទទួលថ្នាំបង្ការរោគ ។ បើអ្នកមានគ្រុនផ្តាសាយធុនស្រាល ឬមានជំងឺផ្សេងៗទៀត តាមធម្មតាមិនបាច់រង់ចាំទេ ។

ត្រូវប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកធ្លាប់មាន :
- ប្រតិកម្មដែលគំរាមកំហែងជីវិត បន្ទាប់ពីទទួលថ្នាំបង្ការរោគគ្រុនផ្តាសាយធំតាមរដូវ
- រោគ Guillain-Barré Syndrome (ជារោគកំរើកល្បែចដ៏ធ្ងន់ធ្ងរ ដែលកំហៅកាត់ថា GBS ដែរ) ។

ថ្នាំទាំងនេះអាចនឹងមិនមែនជាមូលហេតុ ដើម្បីជៀសវាងថ្នាំបង្ការរោគទេ ប៉ុន្តែបុគ្គលិកពេទ្យអាចជួយអ្នកសំរេចបាន ។

ថ្នាំ 2009 H1N1 LAIV អាចនឹងឲ្យនៅពេលដូចគ្នា ដូចថ្នាំបង្ការរោគភាគច្រើនផ្សេងៗទៀតដែរ ។ ត្រូវប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកបានទទួលថ្នាំបង្ការរោគអ្វីមួយផ្សេងទៀត ក្នុងខែកន្លងមក ឬបំរុងនឹងទទួលថ្នាំបង្ការរោគអ្វីមួយ ក្នុងខែបន្ទាប់ទៀត ។ ថ្នាំ H1N1 LAIV និងថ្នាំ LAIV តាមរដូវ មិនគួរឲ្យនៅពេលព្រមគ្នាឡើយ ។

## 6 តើមានគ្រោះថ្នាក់អ្វីខ្លះ បណ្តាលមកពីថ្នាំ 2009 H1N1 LAIV?

ថ្នាំបង្ការរោគ ក៏ដូចនឹងថ្នាំផ្សេងៗទៀតដែរ ដែលអាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជាមានប្រតិកម្មខ្លាំង ជាដើម ។ ប៉ុន្តែភាពគ្រោះថ្នាក់នៃថ្នាំបង្ការរោគណាមួយ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬស្លាប់ គឺមានតិចតួចពេកណាស់ ។

ភាពគ្រោះថ្នាក់កើតចេញអំពីថ្នាំ 2009 H1N1 LAIV ត្រូវបានរំពឹងថាមានភាពស្រដៀងគ្នានឹងថ្នាំ LAIV តាមរដូវដែរ :

បញ្ហាស្រាលៗ :
គេបានរាយការណ៍ថា កូនក្មេង និងក្មេងជំទង់ៗមួយចំនួន ពីអាយុ 2-17 ឆ្នាំ មានប្រតិកម្មធុនស្រាល រួមមានទូវ :
- ការហៀរសំបោរ ការតឹងច្រមុះ ឬក្អក
- គ្រុនក្តៅ
- ឈឺក្បាល និងឈឺសាច់ដុំ
- ការតឹងដង្ហើម
- ឈឺដំបារពោះ ឬការក្អួតចង្អោរ ឬចុះរាក ម្តងម្កាល

DCH–1470CA
AUTH: P.H.S., Act 42, Sect. 2126.

គេបានរាយការណ៍ថា មនុស្សចាស់មួយចំនួន ពីអាយុ 18-49 ឆ្នាំ មាន :
- ការហៀរសំបោរ ឬការតឹងច្រមុះ
- ឈឺបំពង់ក
- ក្អក គ្រេវគ្រាញ អស់កំឡាំង/ខ្សោយកំឡាំង
- ឈឺក្បាល

**បញ្ហាធ្ងន់ធ្ងរ :**
- ប្រតិកម្មដែលគំរាមកំហែងជីវិត ទៅនឹងថ្នាំបង្ការរោគ គឺកម្រមានណាស់ ។ បើសិនជាវាកើតឡើង តាមធម្មតាវាមានក្នុងពេលពីរបីនាទី ទៅពីរបីម៉ោង បន្ទាប់ពីបានទទួលថ្នាំបង្ការរោគ ។
- នៅក្នុងឆ្នាំ 1976 ប្រភេទដំបូងនៃថ្នាំបង្ការសូករោគផ្តាសាយ (swine flu ឬគ្រុនផ្តាសាយជ្រូក) បានជាប់ទាក់ទងជាមួយនឹងករណីនៃរោគ Guillain-Barré Syndrome (GBS) ។ ថ្នាំ LAIV មិនជាប់ទាក់ទងទៅនឹងរោគ GBS ទេ ។

## 7 ចុះបើសិនជាមានប្រតិកម្មធ្ងន់ធ្ងរវិញនោះ?

**តើខ្ញុំគួរតែឃ្លាំរកមើលអ្វី?**
លក្ខណៈចំឡែកអ្វីមួយខុសពីធម្មតា ដូចជាគ្រុនក្តៅខ្លាំង ឬអាកប្បកិរិយាប្រែប្រួល ។ សញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ អាចរួមមាន ការពិបាកដកដង្ហើម ស្អកសំឡេង ឬការតឹងដង្ហើម មានកន្ទួលលើស្បែក ស្លេកស្លាំង ខ្សោយកំឡាំង ចង្វាក់បេះដូងដើរញាប់ៗ ឬវិលមុខ ។

**តើខ្ញុំត្រូវធ្វើយ៉ាងណា?**
- ទូរស័ព្ទទៅគ្រូពេទ្យ ឬយកមនុស្សនោះទៅជួបគ្រូពេទ្យជាបន្ទាន់ ។
- ប្រាប់គ្រូពេទ្យ អំពីអ្វីដែលបានកើតឡើង បានកើតឡើងនៅថ្ងៃខែឆ្នាំណា និងវេលាម៉ោងប៉ុន្មាន ហើយបានទទួលថ្នាំបង្ការរោគពីពេលណា ។
- ស្នើគ្រូពេទ្យរបស់អ្នក ឲ្យរាយការណ៍អំពីប្រតិកម្ម ដោយបំពេញក្រដាសប្រព័ន្ធរបាយការណ៍ព្រឹត្តិការណ៍ប្រតិកម្មថ្នាំបង្ការរោគ (Vaccine Adverse Event Reporting System - VAERS) ។ ឬអ្នកអាចបំពេញសេចក្តីរាយការណ៍នេះ តាមវ៉ិបសៃត៍របស់ VAERS នៅឯ **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅលេខ **1-800-822-7967** ។

*VAERS មិនផ្តល់ឱវាទផ្នែកសុខភាពឡើយ ។*

## 8 ការធានារ៉ាប់រងគ្រោះថ្នាក់ បណ្តាលមកពីថ្នាំបង្ការរោគ

បើរូបអ្នក ឬកូនរបស់អ្នក មានប្រតិកម្មទៅនឹងថ្នាំបង្ការរោគ សមត្ថភាពរបស់អ្នកដើម្បីប្តឹងផ្តល់ គឺបានកំរិតដោយច្បាប់ ។

តែជាយ៉ាងណាមិញ កម្មវិធីនៃរដ្ឋបាលសហព័ន្ធ បានបង្កើតឡើងដើម្បីជួយបង់ថ្លៃការថែទាំរោគ និងការចំណាយផ្សេងៗទៀត សំរាប់មនុស្សមួយចំនួន ដែលមានប្រតិកម្មធ្ងន់ធ្ងរ ទៅនឹងថ្នាំបង្ការរោគនេះ ។ សំរាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ សូមទូរស័ព្ទលេខ **1-888-275-4772** ឬមើលវ៉ិបសៃត៍របស់កម្មវិធី នៅឯ : **www.hrsa.gov/countermeasurescomp/default.htm** ។

## 9 តើខ្ញុំធ្វើយ៉ាងណា ឲ្យបានយល់ដឹងបន្ថែមទៀត?

- សាកសួរគ្រូពេទ្យរបស់អ្នក ។ គេអាចផ្តល់ព័ត៌មានដែលមានភ្ជាប់ជាមួយប្រអប់ថ្នាំ ឬផ្តល់យោបល់អំពីប្រភពព័ត៌មានផ្សេងៗទៀត ។ 1–888–767–4687
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលប្រចាំតំបន់ ឬក្រសួងសុខាភិបាលរដ្ឋ ។
- សូមទាក់ទងទៅមណ្ឌលសំរាប់ទប់ស្កាត់ និងបង្ការជំងឺ (Centers for Disease Control and Prevention - CDC) :
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - សូមមើលវ៉ិបសៃត៍របស់ CDC នៅ **www.cdc.gov/h1n1flu** ឬ **www.cdc.gov/flu**
  - សូមមើលវ៉ិបសៃត៍នៅឯ **www. flu.gov**

DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION

Vaccine Information Statement
2009 H1N1 LAIV IMM-979CA – Cambodian 10/2/09 42 U.S.C. §300aa-26
Translated by Transcend Translations, Davis, CA www.transcend.net

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណៈត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ព័ត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។